**Program:** ឃាតកម្មមុនចូលគេង

**Topic:** Peter Woodcock

(ឃាតករោគចិត្ត ដែលប្រមាញ់កូនក្មេង)

**Categories:** Crime Investigation

**Check: Done**

**Content by:** Prey Reung

---

សូមស្វាគមន៍មកកាន់CamID Podcast!

តើអ្នកទាំងអស់គ្នាធ្លាប់ខ្លាចដែរទេអំពីរឿងប្រមាត់ប្រម៉ង់?
ថ្ងៃនេះព្រៃរឿងនឹងលើកយករឿងរ៉ាវមួយដែលនិយាយអំពីឃាតកេរោគចិត្តវ័យក្មេងម្នាក់ដែលចាប់ក្មេងស្រីប្រុសមកបំពាននិងសម្លាប់យ៉ាងសាហាវឃោរឃៅជាទីបំផុត។ឃាតកម្នាក់នេះពិតជាស្អប់ក្មេងៗខ្លាំងណាស់ ហើយគេតែងតែធ្វើបាបក្មេងៗជានិច្ច។ ក្រៅពីនេះ
ទោះបីជាគេត្រូវជាប់ឃុំហើយក៏ដោយក៏គេអាចសម្លាប់មនុស្សនៅទីនោះផងដែរ សំណួរសួរថា
ហេតុអ្វីបានគេស្អប់និងចូលចិត្តធ្វើបាបក្មេងៗម្ល៉េះ?តើឃាតកជាអ្នកណា?ហើយហេតុអ្វីបានជាគេអាំចសម្លាប់មនុស្សនៅក្នុងមន្ទីរឃុំឃាំងបាន?ដើម្បីអោយដឹងរឿងកាន់តែច្បាស់
តោះមកស្តាប់ព្រៃរឿងបកស្រាយទាំងអស់គ្នា!

រឿងនេះនឹងនាំអ្នកទាំងអស់គ្នាអោយមកស្គាល់ក្មេងប្រុសសាមញ្ញម្នាក់ដែលមានឈ្មោះថា  Peter Woodcock ។ Peter កើតនៅថ្ងៃទី៥ ខែមីនា ឆ្នាំ ១៩៣៩ នៅក្នុងក្រុងPeterborough ខេត្ត Ontario នៃប្រទេសកាណាដា ។ម្តាយរបស់គេទើបតែមានអាយុ១៧ឆ្នាំតែប៉ុណ្ណោះ ហើយជីវភាពរបស់គាត់មានការលំបាកខ្លាំងណាស់ ព្រោះមុខរបរគាត់គឺជាកម្មកររោងចក្រ ។Peter មិនសូវញ៉ាំអាហារនោះទេ ហើយគេតែងតែយំជានិច្ច ។ត្រឹមតែរយះពេលមួយខែបន្ទាប់ពីគេបានកើតមក ម្តាយរបស់គេក៏បោះបង់គេចោលនៅឯមណ្ឌលកុមារកំព្រា ។

ក្រោយមក Peter នៅតែបន្តយំជារឿយៗ ហើយនៅពេលដែលមាននរណាម្នាក់មកក្បែរគេ គេតែងតែស្រែក និងយំគ្រប់ពេលវេលារហូតគ្មានអ្នកណាអាចកាន់គេបានឡើយ ។អស់រយះពេល៣ឆ្នាំ Peter តែងតែប្តូរទៅនៅពីគ្រួសារចិញ្ចឹមមួយទៅគ្រួសារចិញ្ចឹមមួយទៀត ព្រោះគេគឺជាក្មេងដែលពិបាកគ្រប់គ្រងណាស់ ។ម្យ៉ាងវិញទៀត ក្នុងចំណោមគ្រួសារទាំងនោះ មានគ្រួសារមួយដែលតែងតែធ្វើបាប Peter ទាំងផ្លូវកាយនិងផ្លូវចិត្តរហូតដល់រូបគេចូលពេទ្យសង្គ្រោះបន្ទាន់ទៀតផង ព្រោះពេលនោះករបស់គេគ្រេច ។

យ៉ាងណាមិញជីវិតរបស់ Peter  ក៏បានផ្លាស់ប្តូរ នៅពេលដែលគេត្រូវបានគ្រួសារជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តមមួយរបស់លោកFrank និងអ្នកស្រី Susan Maynard ។ពួកគេទាំងពីរក៏ យក Peter មកចិញ្ចឹមបូករួមទាំងការចំណាយលើថ្លៃព្យាបាល សាលារៀន

និងសម្ភារៈផ្សេងៗគ្រប់សព្វបែបយ៉ាងទាំងអស់។ទោះបីជាយ៉ាងណាក៏ដោយ Peter

មិនចេះប្រើប្រាស់របស់របរ

លុយកាក់ទាំងនោះអោយមានតម្លៃស្របទៅតាមជីវិតគេនោះឡើយ។នៅអាយុ5ឆ្នាំ Peter ឈប់យំ

នៅពេលដែលមានមនុស្សមកជិតគេ ក៏ប៉ុន្តែគ្រានោះគេត្រូវបានគេនិយាយតគ្នាថា

នៅតែជាក្មេងប្រុសចម្លែកដែលមិនសូវចុះសម្រុងជាមួយអ្នកដទៃដដែរ។

ឪពុកម្តាយចិញ្ចឹមរបស់Peter មានការបារម្មណ៍អំពីភាពចម្លែករបស់គេខ្លាំងណាស់

ហើយក្រោយមកក៏បញ្ជូន Peter

ទៅព្យាបាលនៅមន្ទីពេទ្យកុមារ។នៅទីនោះគ្រូពេទ្យយកចិត្តទុកដាក់ព្យាបាលរូបគេមែនទែន

ក៏ប៉ុន្តែការព្យាបាលជម្ងឺផ្លូវចិត្តនៅជំនាន់នោះមិនសូវជាមានប្រសិទ្ធភាពដូចបច្ចុប្បន្ននោះទេ។

រូបរាងនិងភាពចម្លែករបស់គេបានធ្វើឱ្យគេក្លាយជាទៅជាគោលដៅសម្រាប់ការមើលងាយ ហើយជារឿយៗ

Peter ត្រូវបានគេរកឃើញថាចូលចិត្តលាក់ខ្លួន ព្រោះគេមិនចង់លឺពាក្យសម្តីម៉ាក់ងាយទាំងនោះឡើយ។

មានពេលមួយPeterត្រូវបានគេរកឃើញថា គេកំពិងលក់ខ្លួននៅក្នុងព្រៃដើម្បីគេចពីពាក្យសម្តីទាំងនោះ

តែគេបាននិយាយថាគេគ្រាន់តែចង់រកកន្លែងមួយដើម្បីចង់អោយព្រះជាម្ចាស់ឃើញគេតែប៉ុណ្ណោះ។

នៅពេលPeterអាយុ ១១ ឆ្នាំ Peter ក៏បានចូលរួមកម្មវិធីតាំងពីពណ៌មួយរបស់ប្រទេសកាណាដា

ដែលមានអ្នកសង្គមកិច្ចចូលរួមជាច្រើននៅក្នុងនោះ។ពួកគេទាំងនោះក៏បានលឺពាក្យម្យ៉ាងដែលចេញពីមា

ត់របស់Peter ដោយពាក្យនោះមានអត្ថន័យថា “ខ្ញុំបន់អោយតែមានគ្រាប់បែកមួយទម្លាក់មក

ដើម្បីបំផ្ទុះក្មេងៗនៅទីនេះស្លាប់ទាំងអស់”។ពាក្យទាំងនេះស្តែងអោយយើងដឹងថា សេចក្តីស្អប់របស់គេចំពោះក្មេងបានដក់ជាប់ក្នុងចិត្តគេបាត់ទៅហើយ។អ្នកសង្គមកិច្ចទាំងនោះយក Peterទៅព្យាបាលម្តងទៀតនៅឯមន្ទីពេទ្យ តែជាអកុសល វាមិនអាចធ្វើអ្វីដើម្បីលុបលាងចិត្តដ៏ឃោរឃៅរបស់គេនោះទេ។

នៅពេលដែលPeterចាប់ផ្តើមធំដឹងក្តី Peter ក៏ចេះចាប់ផ្តើមជិះកង់។ពីមួយថ្ងៃទៅមួយថ្ងៃគេតែងតែជិះកង់ដើរលេងជុំវិញ ទីក្រុងToronto ដើម្បីមើលទិដ្ឋភាពជុំវិញទីក្រុងនោះ។ជិះចុះជិះឡើង គេក៏ឃើញក្មេងទំនើងមួយក្រុម ហើយគេក៏កើតក្តីស្រម៉ៃចង់ក្លាយជាមេក្រុមក្មេងទំនើងដើម្បីធ្វើបាបក្មេងៗនៅតំបន់នោះ។

អ្វីដែល Peter ចាប់អារម្មណ៏ជាងគេនៅពេលនេះ គឺរាងកាយមនុស្ស។ពេលនៅផ្ទះគេចូលចិត្តអានសៀវភៅ ដែលទាក់ទងនឹងរឿងរ៉ាវទាំងនេះ ជាពិសេសគេក៏ចាប់ផ្តើមចង់ដឹងរឿងដែលទាក់ទងនឹងផ្លូវភេទតែម្តង។មិនយូរប៉ុន្មាន Peter បានចាប់ជម្រិតក្មេងៗនៅជិតនោះដោយលួងលោមយកពួកក្មេងទាំងនោះអោយមកជិះកង់ជាមួយគេ។ នៅពេលដែលPeter នាំពួកគេទៅដល់កន្លែងស្ងាត់ Peter ចាប់ផ្តើមធ្វើសកម្មភាពបំពានពួកគេម្តងបន្តិចរហូតដល់ក្មេងទាំងនោះភ័យបាត់បង់ស្មារតី និងមានពេលខ្លះ Peterថែមទាំងដោះខោអាវពួកគេចេញទៀតផង។

តាំងពីពេលនោះមកPeter ចេះតែធ្វើសកម្មភាពចម្លែកៗបន្តបន្ទាប់រហូតដល់ថ្ងៃមួយ ពោលគឺនៅឆ្នាំ 1956 Peter បានចាប់ក្មេងម្នាក់ដែលមាន ឈ្មោះថា Wayne Mallett អាយុ 7 ឆ្នាំចេញពីកន្លែងតាំងពិពណ៌មួយ ហើយPeterបានប្របាច់កក្មេងនោះរហូតដល់ស្លាប់។ នៅពេលPeterចាកចេញពីកន្លែងកើតហេតុ Peter បាននិយាយជាមួយសន្តិសុខដោយចំឡែកថា គេបានឃើញមនុស្សម្នាក់ដែលមើលទៅដូចជាខ្លួនគេដែលបានរត់ចេញពីតំបន់នោះ។ សាកសពរបស់ Wayne Mallett ក៏ត្រូវបានរកឃើញនៅថ្ងៃបន្ទាប់។ Peter ហាក់ដូចជាត្រូវបានគេវាយប្រហារ ព្រោះមើលទៅគេមានស្នាមខាំមួយនៅលើខ្លួនរបស់គេ។

ក្រុមប៉ូលិសក៏សង្ស័យថា ប្រហែលជាPeter ត្រូវបានឃាតកវាយធ្វើបាបហើយមើលទៅ។ប៉ូលីសក៏បានចាប់ខ្លួនក្មេងប្រុសម្នាក់ឈ្មោះថា Ron Moffatt ពីបទឧក្រិដ្ឋនោះ បើទោះបីជា Ron មានកុស្តតាងប្រកែកជាមួយប៉ូលិសហើយក៏ដោយ។ Ron ទើបតែមានអាយុ១៤ឆ្នាំតែប៉ុណ្ណោះ។

គួរបញ្ជាក់ផងដែរថា Ron នេះហើយគឺជាអ្នកជាប់ជានក្នុងក្ដីឃាតកម្មដែលPeter បានប្រព្រឹត្ត។ ប៉ូលិសក៏បានសួរចម្លើយទៅកាន់ Ron ដោយស្រែកនិងនិយាយខ្លាំងដាក់Ron។ដោយRon មានភាពភ័យខ្លាចចំពោះប៉ូលិស Ronក៏បានសារភាពចំពោះឧក្រិដ្ឋកម្មនេះទាំងដែរខ្លួនមិនមានកំហុស។ Ronត្រូវបានតុលាការកាត់ទោសឱ្យឃុំខ្លួនក្នុងមណ្ឌលកែប្រែរហូតដល់ឆ្នាំ១៩៥៧។

ពេលវេលាក៏បានអូសបន្លាយរហូតមកដល់ នៅខែតុលា ឆ្នាំ 1956 Peter បានចាប់ក្មេងម្នាក់ទៀតមកសម្លាប់ ក្មេងម្នាក់នោះមានឈ្មោះថា Gary Morris អាយុ 9 នៅ Cabbagetown ។ គេបានជិះកង់ដឹក Gary ទៅឆ្នេរ Cherry ដែលជាកន្លែងដែល Peter បានវាយ និងប្របាច់កក្មេងប្រុសនោះរហូតដល់ស្លាប់។សាកសពរបស់ Gary មើលទៅត្រូវបាន Peter ដោះសម្លៀកបំពាក់ រួចពាក់ឡើងវិញ។

ងាកមកមើលជនរងគ្រោះទី៣វិញ គឺជាក្មេងស្រីដែលមានឈ្មោះថា Carol Voyce។Peter បានធ្វើសកម្មភាពជាថ្មីម្ដងទៀតដោយរូបគេបានចាប់ Carol ចេញពីផ្ទះរបស់នាង និងដាក់នៅលើកង់របស់គេតែម្ដង រួចហើយគេបានជិះកង់ទៅតំបន់មួយដែលមានឈ្មោះថា Bloor Viaduct។ ពេលទៅដល់ Peter ក៏ចាប់បំពានរាងកាយនាង ហើយផ្ទប់ដង្ហើមនាងរហូតដល់បាត់បង់ស្មារតី។ក្រុមអ្នកពិនិត្យសាកសាពបាននិយាយថា  Carol ស្លាប់ដោយសារតែ Peter យកមែកឈើទៅបំពានអាវយវផ្លូវភេទរបស់នាង។Carol ស្លាប់យ៉ាវវេទានាជាទីបំផុត។

ចៃដន្យ Peter ក៏ត្រូវបានគេប្រទះឃើញចាកចេញពីកន្លែងកើតហេតុនោះ។ គេថែមទាំងបាននិយាយទៅកាន់អ្នកនៅក្បែរនោះទៀតផង គេនិយាយថា "ប្រសិនបើពួកគេរកឃើញសាកសពនៅទីនោះ ពួកគេនឹងគិតថាវាជាខ្ញុំ"។ សាក្សីនៅទីនោះក៏បានយករឿងនោះទៅប្រាប់ប៉ូលិស និងប្រាប់ពីភិនភាគរបស់Peter និងកង់របស់គេ។

មិនយូរប៉ុន្មាន នៅថ្ងៃទី 21 ខែមករាឆ្នាំ 1957 Peter ក៏ត្រូវបានចាប់ខ្លួន។ Peter មានការភ័យខ្លាចខ្លាំងមែន ប៉ុន្តែការភ័យខ្លាចរបស់គេនៅពេលនោះ មិនមែនគេមានបញ្ហាប្រឈមមុខនឹងច្បាប់នោះទេ តាមការពិត គេខ្លាចម្ដាយរបស់គេដឹងអំពីឧក្រិដ្ឋកម្មរបស់គេទៅវិញទេ។ទីបំផុត គេក៏បានសារភាពចំពោះអំពើមនុស្សឃាតទាំងប៉ុន្មានដែលគេបានប្រព្រឹត្ត។

Peter មិនត្រូវបានជាប់ទោសអ្វីនោះទេ ព្រោះដោយសារតែគេមានជម្ងឺឆ្កួតជ្រូក ហើយក៏ត្រូវបានបញ្ជូនអោយទៅមណ្ឌលឃុំឃាំងមួយដែលនៅទីក្រុងOntarioដែលជាកន្លែងដាក់អ្នកទោ

សដែលមានជម្ងឺផ្លូវចិត្ត

ដែលមានប្រព័ន្ធការពារតឹងរឹងបំផុតនៅប្រទេសកាណាដា ។ហើយរឿងរ៉ាវរបស់គេមិនទាន់ចប់ត្រឹមនេះ

នោះទេ ។សំណួរសួរថា តើមានរឿងអ្វីបន្ទាប់ពីនេះ ?

ទៅដល់ទីនោះPeter ត្រូវបានវេជ្ជបណ្ឌិតអោយអោយថ្នាំឆ្លួតជ្រូកម៉្យាងអោយគេលេបដើម្បីព្យាបាល

ហើយមើលទៅគេហាក់បីដូចជាចូលចិត្តថ្នាំនោះណាស់

ផ្ទុយទៅវិញថ្នាំនោះមិនអាចមានព្យាបាលគេបាននោះទេ ។ជម្ងឺរបស់គេមិនត្រឹមតែរើឡើងវិញនោះទេ

គេថែមទាំងរាប់អានមិត្តទាំងនោះដើម្បីយកបារីដក់ទៀតផង ។រឿងដែលនឹកស្មានមិនដល់នោះគេថែមទាំង

មានទំនាក់ទំនងផ្លូវភេទជាមួយពួកអ្នកទាំងនោះទៀតផង ។

ថ្ងៃមួយ Peter ក៏ត្រូវបានគេបញ្ជូនអោយទៅនៅក្នុងមណ្ឌលមួយកន្លែងទៀតដោយចៃដន្យ

ដោយកន្លែងនោះមានប្រព័ន្ធកាពារទោបជាងកន្លែងចាស់

ហើយថែមទាំងត្រូវបានគេអនុញ្ញាតអោយទៅមើលសារមន្ទី

និងមើលភាពយន្តនៅរោងកុនទៀតផង ។ខណះពេលនោះហើយ Peter

មានឱកាសប្តូរឈ្មោះរបស់មួយទៀតដោយខុសច្បាប់ ដែលមានឈ្មោះថា David Michael

Krueger ។ដើម្បីកុំអោយអ្នកទាំងអស់គ្នាយល់ច្រឡំ ព្រៃរឿងសុំហៅគេថាឈ្មោះគេថា Peter ដដែរ ។

គ្រានោះPeter ក៏ក្លាយទៅជាមិត្តភក្តិជាមួយអតីតអ្នកជម្ងឺម្នាក់

និងក្លាយជាមិត្តសន្តិសុខអ្នកយាមនៅទីនោះផងដែរ ។សន្តិសុខនោះមានឈ្មោះថា Bruce Hamill ។

ក្រោយមក Peter ក៏បានបញ្ចុះបញ្ចូល Bruce ថាភាពជាបងប្អូននឹងគ្នា

អាចដោះស្រាយបញ្ហាទាំងអស់របស់ពួកគេទាំងពីរបើពួកគេសហការណ៏គ្នាបានល្អ ។Peter

ក៏បានបង្គាប់អោយ  Bruce ជួយគេក្នុងការសម្លាប់ Dennis Kerr ដែលជាអ្នកទោសម្នាក់ទៀត

និងជាសត្រូវរបស់គេ។លុះមកដល់ខែកក្កដា ឆ្នាំ 1991 Bruce បានទៅហាងមួយ ហើយបានទិញរបស់របរមួយចំនួន រួមទាំងម្ជុក និងកាំបិតមួយចំនួន ហើយបន្ទាប់មកក៏បានដាក់ម៉ូជាមួយ Peter អោយគេចេញពីទីកន្លែងនេះ។

ក្នុងរយៈពេលមួយម៉ោងក្រោយមក បន្ទាប់ចេញពីមន្ទីរពេទ្យ Peter និងBruce បានជួបជាមួយ Dennis ដោយធ្វើពុតជាខ្ចីប្រាក់គាត់ចំនួន 500 ដុល្លារ។ ដោយមិនចាំយូរ Peter និងBruce បានស្ទាក់ចាប់ Dennis ដោយសម្លាប់គាត់ និងកាត់សាកសពគាត់ជាបំណែកៗ។ បន្ទាប់ពីពួកគេបានសម្លាប់ Dennis នៅក្នុងថ្លុកឈាមហើយ ពួកគេទាំងពីរក៏បានបំពានទៅលើសាកសពរបស់Dennis។ បន្ទាប់មក Peter បានពាក់អាវរបស់គេវិញ ហើយទុក Bruce នៅកន្លែងកើតហេតុនោះ ហើយគេក៏រត់ទៅហៅប៉ូលីសដែលនៅជិតនោះ ដើម្បីសារភាពថាគេជាអ្នកសម្លាប់។

រឿងក៏ចប់ត្រឹមចំណុចនេះ ដោយចុងក្រោយ Peterក៏ត្រូវបានគេបញ្ជូនត្រឡប់ទៅមណ្ឌលសុខភាពផ្លូវចិត្តដែលមានសុវត្ថិភាពខ្ពស់វិញ ដែលគេបានចំណាយពេលនៅទីនោះអស់រយៈពេល៣៤ ឆ្នាំ រហូតដល់ថ្ងៃដែលគេបាត់បង់ជីវិតនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១០។ហើយអ្វីដែលអ្នកទាំងអស់គ្នាមិនទាន់ដឹងនោះគឺ គេប្រហែលជាបានធ្វើបាបក្មេងជិត១០០នាក់។ គេពូកែគេចពីការចាប់ខ្លួន និងចល័តគ្រប់ទីកន្លែង ដើម្បីបោកបញ្ឆោតក្មេងៗពីតំបន់ផ្សេងៗក្នុងទីក្រុង។

ចំណុចដែលអ្នកទាំងអស់គ្នាគួរតែស្វែងយល់ក្នុងរឿងរ៉ាវនេះ គឺការខ្វះការថែទាំ និងភាពខ្វះទំនួលខុសត្រូវរបស់ឪពុកម្តាយទៅលើកុមារពិតជាអាចជះឥទ្ធិពលទៅដល់ពួកគេនៅថ្ងៃអនាគត ហើយជាពិសេសនោះក្មេងទាំងនោះច្បាស់ជាមានអារម្មណ៍មួយថាឃ្លាតពីអ្នកជុំវិញខ្លួន។ម្យ៉ាងវិញទៀតពា

ក្យយើងគួរតែលុបបំបាត់ពាក្យទាំងឡាយណាដែលមើលងាយអ្នកដទៃចាប់ពីពេលនេះទៅ ព្រោះថាយើងមិនអាចមើលឃើញថាពាក្យទាំងនោះប៉ះពាល់ដល់សតិអារម្មណ៏របស់ពួកគេនៅថ្ងៃមុខនោះទេ ។ពាក្យសម្តីអាចប្រែមនុស្សស្លូតត្រង់អោយក្លាយទៅជាកាចសាហាវក៏ថាបាន ។សូមស្តាប់ដោយការត្រិះរិះពិចារណា!

Links and Resources

https://murderpedia.org/male.K/k/krueger-david.htm
https://www.thestar.com/news/ontario/2010/03/09/the_serial_killer_they_couldnt_cure_dies_behind_bars.html
https://zeph456.medium.com/peter-woodcock-canadas-youngest-serial-killer-4fd3a2f621e6